*រាជធានីភ្នំពេញថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ១៩៩៤*

**អនុក្រឹត្យ លេខ ៥៥**
**ស្តីពីការបង្កើតបញ្ជាការដ្ឋាន**
**តំបន់ប្រតិបត្តិការសឹករងឧត្តរមានជ័យ**

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតអគ្គសេនាធិការដ្ឋានកងទ័ពជាតិកម្ពុជា ។

-ផ្អែកតាមសំណូមពរចាំបាច់នៃកងយោធពលខេមរភូមិន្ទ ចំពោះមុខ ។

-ផ្អែកតាមសំណើរបស់នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ ។

**សំរេច**

មាត្រា ១ : ត្រូវបានបង្កើតបញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹករង ឧត្តរមានជ័យ ស្ថិតនៅក្រោមការដឹកនាំបញ្ជាផ្ទាល់របស់យោធភូមិភាគទី៤ ។

មាត្រា ២ : រចនាសម្ព័ន្ធចាត់តាំងភារកិច្ច និងសិទ្ធិរបស់តំបន់ប្រតិបត្តិការសឹករង ឧត្តរមានជ័យ អាស្រ័យដោយអគ្គសេនាធិការកំណត់ ។

មាត្រា ៣ : ប្រគល់ជូនអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទធ្វើការកំណត់ភារកិច្ច និង ពេលវេលាជាក់ស្តែងក្នុងការរៀបចំបញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹករង ខាងលើ ។

មាត្រា ៤ : អគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទត្រូវទទួលបន្ទុកអនុវត្តន៍អនុក្រឹត្យនេះ ។

មាត្រា ៥ : អនុក្រឹត្យនេះចូលជាធរមានចាប់ពីពេលឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

*រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ១៩៩៤*

## អនុក្រឹត្យ លេខ ៥៦ អនក្រ
## ស្តីពីការបង្កើតសេនាធិការដ្ឋាន
## កងរាជអាវុធហត្ថ ស្វាយរៀង ព្រៃវែង
## កណ្តាល កំពង់ឆ្នាំង កំពង់ស្ពឺ ស្ទឹងត្រែង

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃព្រះរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញក្រឹត្យចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតសេនាធិការដ្ឋាន កងទ័ពជាតិកម្ពុជា ។

-ផ្អែកតាមសំណូមពរនៃការកសាងកងរាជអាវុធហត្ថ ឆ្នាំ ១៩៩៤ និងបង្កើនការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម បង្ក្រាបរាល់អំពើល្មើសច្បាប់។

-ផ្អែកតាមសំណើរបស់នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ ។